ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល　　　　　　　　ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងរដ្ឋប្បវេណី　　　　　　**អាទនាមប្រជារាស្ត្រខ្មែរ**

លេខ : ១៨៦　　　　　　　　**តុលាការកំពូល**

ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០២

**សាលដីកា**

លេខ : ២៩៣

ចុះថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ២០០២

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ ឆ្នាំ២០០២ ដោយមានសមាសភាព ដូចតទៅ :

១- ឯកឧត្តម ឌិត មុន្ទី ជាប្រធាន

២- លោក ស៊ិន ឌឹម ជាចៅក្រម

៣- លោក ប៉ែន សារឿន ជាចៅក្រម-របាយការណ៍

៤- លោក ប្រាក់ គឹមសាន ជាចៅក្រម

៥- លោក សោម សិរីវឌ្ឍ ជាចៅក្រម

ក្រឡាបញ្ជី

កញ្ញា ហុក សុខចុល

តំណាងមហាអយ្យការ

លោក ឈួន ចន្ថា ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីកាលេខ ១៩"ឈ" ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ២០០២ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៩២៦ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០១របស់សាលាឧទ្ធរណ៍រវាង :

ដើមចោទឈ្មោះ ថាច់ វ៉ាន់ឡុន ( ម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៤៤ឆ្នាំ សញ្ជាតិខ្មែរ មុខរបរពាណិជ្ជករ ទីលំនៅសព្វថ្ងៃផ្ទះលេខ ៤៤E₀ ផ្លូវព្រះនរោត្តម សង្កាត់ផ្សារកណ្តាលទីII ខណ្ឌដូនពេញ ក្រុងភ្នំពេញ ។ ឪពុកឈ្មោះ ថាច់ ឈាង (ស្លាប់) ម្តាយឈ្មោះ អ៊ុក ខុន មានកូន០១នាក់ ។

- មានមេធាវីលោក ទូត លុច ។

ចុងចម្លើយឈ្មោះ ឈឹម វត្តី ភេទស្រី ( ចុងបណ្តឹងសាទុក្ខ) អាយុ៤២ឆ្នាំ ជាតិខ្មែរ របររកស៊ីលក់ដូរ ទីលំនៅផ្ទះ លេខ៤៤ E₀ ផ្លូវនរោត្តម សង្កាត់ផ្សារកណ្តាលទីII ខណ្ឌដូនពេញ ក្រុងភ្នំពេញ ឪពុកឈ្មោះឈឹម រុំ ម្តាយ ឈ្មោះ ខៀវ ណារ៉ុន ( រស់ ) មានកូនស្រីម្នាក់ ។

- មានមេធាវីលោក ការ សាវុត្ថ និង លោក ហាក់ សៀកលី ។

**កម្មវត្ថុ** ៖ ប្ដឹង សុំផ្ដាច់សមគ្គសង្វាស និង សុំចែកទ្រព្យសម្បត្តិរួម ក្រោយពីទូទាត់បំណុលរួចហើយ ។

បានឃើញបណ្ដឹងសាទុក្ខលេខ ៩៥ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០២ របស់ លោក ទូត លុច (មេធាវីការពារក្ដីឱ្យ លោក ថាច់ វ៉ាន់ឡុន) ប្ដឹងមិនសុខចិត្តនឹងសេចក្ដីសំរេច របស់សាលាឧទ្ធរណ៍ទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ១៨៦ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០២ របស់តុលាការកំពូល ។

តាមពាក្យបណ្ដឹងចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០០០របស់ដើមចោទឈ្មោះ ថាច់ វ៉ាន់ឡុន ថា ៖ ខ្លួន និង នាងឈឹម វត្តី បានរួមរស់ជាមួយគ្នាតាំងពីឆ្នាំ១៩៨៩មក មានកូនស្រីម្នាក់ឈ្មោះ ថាច់ វ័ត្ត កញ្ញានាមម៉ារី អាយុ០៤ឆ្នាំ ។ រយះពេលកន្លងទៅខ្លួន និង ប្រពន្ធ រស់នៅមិនចុះសម្រុងគ្នា មិនអាចរស់នៅជាមួយគ្នា តទៅទៀតបានឡើយ ហើយសព្វថ្ងៃនេះបានបែក លំនៅ សង្វាសពីគ្នារួចដែរ ហេតុនេះខ្លួនសូមប្ដឹងសុំផ្ដាច់សមគ្គសង្វាស ពីប្រពន្ធឈ្មោះ ឈឹម វត្តី សុំចែកទ្រព្យសម្បត្តិរួម និងសុំយកកូនទៅចិញ្ចឹមថែរក្សា ។

តាមពាក្យបណ្ដឹងចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០០ របស់នាងឈឹម វត្តី ថា ៖ លោក ថាច់ វ៉ាន់ឡុន បានលួចបើកក្រុមហ៊ុនថ្មី ឈ្មោះអិលអេសអេស សង់តាណា និង បើកគណនីថ្មី លេខ ៣៣២ ០៤៦០៨ នៅធនាគារអង្គរ ដោយមិនបានឱ្យខ្លួនដឹងពីការធ្វើ សេវាកម្មថ្មីទៀត ដែលមានគណនីលេខ 0000 ៣៥៦៨ ២២៥ នៅធនាគារ BNP នៅប្រទេសបារាំងហើយលោក ថាច់ វ៉ាន់ឡុន បានផ្ទេរថវិកា ពីក្រុមហ៊ុន អិលតេលុច្សអស់ទៅហើយ ទើបគាត់ដាក់ពាក្យប្ដឹង ផ្ដាច់សមគ្គសង្វាសពីខ្លួនដែលអំពើ ទុកឱ្យខ្លួន និង កូន ត្រូវទទួលរងនូវបំណុលដ៏ច្រើនក្នុងក្រុមហ៊ុនចាស់ ហេតុនេះខ្លួនសុំប្ដឹង ឃាត់ការបន្តសេវាកម្ម របស់ក្រុមហ៊ុនអិលអេសអេស សង់តាណា ចុះបញ្ជីពាណិជ្ជកម្មលេខ ៤៤៥៥/៩៩P ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ១៩៩៩ របស់លោក ថាច់ វ៉ាន់ឡុន ជាបណ្ដោះអាសន្ន រង់ចាំតុលាការសំរេចដល់រឿងអង្គសេចក្ដី ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ៦៣ "ខ" ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០០០ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ ៖

១- ទទួលពាក្យបណ្ដឹងរបស់លោកថាច់ វ៉ាន់ឡុន ជាដើមចោទចុះថ្ងៃទី២៨ ខែ មករា ឆ្នាំ២០០០ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២- អោយលោក ថាច់ វ៉ាន់ឡុន និង នាងឈឹម វត្តី ដាច់សមគ្គសង្វាស់ពីគ្នា ចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ តាមការព្រមព្រៀង របស់គូភាគី (យោងតាមមាត្រាទី៥៨ នៃច្បាប់

អាពាហ៍ពិពាហ៍ និង គ្រួសារ ) ។

៣- អោយនាង ឈឹម វត្តី ស្ថិតនៅក្នុងភាពមេមាយចំនួន៣០០ថ្ងៃ គិតពីថ្ងៃ នេះតទៅ " តាមមាត្រាទី៩ នៃច្បាប់អាពាហ៍ពិពាហ៍ និង គ្រួសារ " ។

៤- ប្រគល់កូនស្រីម្នាក់ឈ្មោះ ថាច់ វ័ត្តកញ្ញានាម៉ារី អាយុ០៤ឆ្នាំ អោយទៅនាង ឈឹម វត្តី ជាម្តាយចិញ្ចឹមបីបាច់ថែរក្សាចាប់ពីថ្ងៃ ប្រកាសសាលក្រមនេះតទៅ ប៉ុន្តែលោកថាច់ វ៉ាន់ឡូន ជាឪពុក ត្រូវបំពេញករណីកិច្ចរបស់ខ្លួន ក្នុងការឧបត្ថម្ភជីវភាពកូនតាមលទ្ធភាព រហូតកូនមាននីតិភាព ។

- លោក ថាច់ វ៉ាន់ឡូន ដែលមិនបានថែរក្សាកូនមានសិទ្ធិទៅសួរសុខទុក្ខកូន ឯនាងឈឹម វត្តី ដែលទទួលសិទ្ធិរក្សាកូនត្រូវបង្កលក្ខណៈងាយស្រួលគ្រប់បែបយ៉ាងដល់ភាគីម្ខាងទៀត ។

៥- ទ្រព្យសម្បត្តិរួមមាន :

១-ផ្ទះសំអាងការលុច្សលេខ ១៥០$E_0$ $E_1$ $E_2$ $E_3$ ផ្លូវលេខ១៤៨ សង្កាត់ផ្សារកណ្តាលទី២ ខ័ណ្ឌដូនពេញ ក្រុងភ្នំពេញមានប័ណ្ណកម្មសិទ្ធិលេខ១៥២២៣ ។

២-ផ្ទះលេខ៥ បន្ទប់លេខ១១៩$E_3$ ផ្លូវលេខ១៥៤ សង្កាត់ផ្សារកណ្តាល២ ខ័ណ្ឌដូនពេញ ក្រុងភ្នំពេញ ។

៣- ផ្ទះពីរល្វែងលេខ១១៩ $E_3$ ផ្លូវលេខ ១៥៤ សង្កាត់ផ្សារកណ្តាលទី២ ខ័ណ្ឌដូនពេញ ក្រុងភ្នំពេញ ។

៤- ទំនិញ និង សំភារៈ បណ្តាក់ក្នុងក្រុមហ៊ុន និង សំភារៈក្នុងហាងមាន : ទឹកអប់ ម៉ាស្សា . សំអាងការ ។

៥- រថយន្តមួយគ្រឿង ម៉ាក្សBMW លេខឃ០១៨៤ ភ៣២

៦- ប័ណ្ណ កម្មសិទ្ធិកាន់កាប់លេខ AIV0332 ទំហំ20A ស្ថិតនៅ ភូមិវត្តបូណ៌ សង្កាត់លេខ០៤ ទីរួមខេត្តសៀមរាប ។

៧-ប័ណ្ណកម្មសិទ្ធិលេខ$G_2$ 0275 ទំហំ14A46CAនៅភូមិចុងព្រែក ឃុំព្រែកឯង ស្រុកកៀនស្វាយ ខេត្តកណ្តាល ។

៨- ប័ណ្ណកម្មសិទ្ធិលេខ ក៣០០០៧៩១ ទំហំ7A20CA នៅភូមិធ្វីខាងជើង ឃុំអណ្តូងខ្មែរ ស្រុកកំពង់បាយ ខេត្តកំពត ។

៩- ប័ណ្ណកម្មសិទ្ធិកាន់កាប់លេខ ក៣ ០០០៧៨៣ ទំហំ6A67CA នៅភូមិធ្វីខាងជើង ឃុំអណ្តូងខ្មែរ ស្រុកកំពង់បាយ ខេត្តកំពត ។

១០- ដីចំការម្នាស់មាន១០ឃ្លង់ ទំហំ13H20A36CA នៅភូមិរលួស ឃុំបឹងទុក ស្រុកកំពត ខេត្តកំពត ។

១១- ដីកសិដ្ឋានចិញ្ចឹមសត្វ មានបីប្លង់ទំហំ11H51A02CA នៅភូមិកែបថ្មី ឃុំបឹងទុក ស្រុកកំពត ខេត្តកំពត ។

១២- ដីចំការមានមួយប្លង់ ទំហំ03H52A00CA នៅភូមិគីឡូ១២ ឃុំកោះតូច ស្រុកកំពត ខេត្តកំពត ។

១៣- ដីចំការ និង ស្រែ មានបីប្លង់ទំហំ02H46A24CA ស្ថិតនៅភូមិរលួស ឃុំបឹងទុក ស្រុកកំពត ខេត្តកំពត ។

១៤- ដីនៅកោះដាច់លេខ J 0827 ត្រូវចែកគ្នាស្មើ ក្រោយពីអ្នកទាំងពីរ បានសងបំណុលរួមរួចហើយ ។

៧- បង្គាប់អោយលោក ថាច់ វ៉ាន់ឡុន បង់ប្រាក់ប្រដាប់ក្ដីចំនួន៧០០០រៀល តាមការស្ម័គ្រចិត្តរបស់ខ្លួន គឺពន្ធប្ដឹងពន្ធចុះបញ្ជីក្ដី១.៨០០រៀល រង្វាន់អ្នកប្រគល់ដីកាកោះ៥.០០០រៀល រង្វាន់ក្រឡាបញ្ជី កាន់ហិបប្រាក់២០០រៀល សរុប ៧.០០០រៀល ប្រាក់នេះដើមចោទ បានបង់រួចហើយ ។

៨- សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខដើមចោទ និង មេធាវីដើមចោទ កំបាំងមុខចុងចំលើយ និង មេធាវី បើកផ្លូវប្ដឹងទាស់ និង ផ្លូវឧទ្ធរណ៍តាមកំណត់ច្បាប់ ។

បានឃើញបណ្ដឹងទាស់របស់ឈ្មោះ ឈឹម វត្តី ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០០ ដោយស្នើសុំឱ្យលោកចៅក្រមធ្វើការជំនុំជំរះករណីនេះឡើងវិញ ដើម្បីឱ្យខ្លួនបានឆ្លើយការពារខ្លួនចំពោះមុខតុលាការផង ។

បានឃើញសាលក្រមលេខ ៥៧ "ខ" ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ ២០០១ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារដូចតទៅ :

១- ទទួលពាក្យបណ្ដឹងទាស់របស់ឈ្មោះ ឈឹម វត្តី ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ ២០០០ ទុកជាត្រឹមត្រូវ តាមទំរង់ច្បាប់ តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២- តំកល់សាលក្រមរដ្ឋប្បវេណីលេខ ៦៣"ខ" ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០០០ ទុកជាបានការពេញ ទាំងមូល តាមច្បាប់ចាប់ពីថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០១ នេះតទៅ ។

៣- សាលក្រមនេះជំនុំជំរះ ជាសាធារណៈ ចំពោះមុខដើមបណ្ដឹង និងមេធាវីការ សាវុត្ថ . ហាក់ សៀកលី និង ចំពោះមុខចុងបណ្ដឹងទាស់ ថាច់ វ៉ាន់ឡុន និងមេធាវី ចុង អៀវហេង ទូត លុច បើកផ្លូវឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

បានឃើញបណ្ដឹងឧទ្ធរណ៍លេខ ១៥"ខ" ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០១ របស់អ្នកស្រី ឈឹម វត្តី ប្ដឹងមិនសុខចិត្តនឹងសេចក្ដីសំរេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ១៤៤ "ឈ" ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១- ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០១ របស់ឈ្មោះ ឈឹម វត្តី ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២- បដិសេធសាលក្រមរដ្ឋប្បវេណីលេខ ៥៧ "ខ" ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ ២០០១ និងលេខ៦៣ "ខ" ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០០០ របស់តុលាការក្រុងភ្នំពេញ ចោលជាអសារបង់។

៣- បដិសេធពាក្យបណ្តឹង សុំផ្តាច់សមគ្គសង្វាស់ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០០០ របស់ឈ្មោះ ថាច់ វ៉ាន់ឡុន ចោលជាអសារបង់ ។

៤- ប្រគល់កូនស្រីម្នាក់ឈ្មោះ ថាច់ រ័ត្នកញ្ញានាម៉ារី អាយុ០៤ឆ្នាំឱ្យទៅអ្នកស្រី ឈឹម វត្តី ជាម្តាយចិញ្ចឹមបីបាច់ថែរក្សាតទៅ ចាប់ពីពេលដែលសាលដីកានេះចូលជាស្ថាពរ ។

៥- សំរេចទុកសិទ្ធិឱ្យលោក ថាច់ វ៉ាន់ឡុន ទៅសួរសុខទុក្ខកូនបាន ។

៦- ប្រគល់ផ្ទះលេខ១៥០$E_0$ $E_1$ $E_2$ $E_3$ ផ្លូវ១៤៨ សង្កាត់ផ្សារកណ្តាលទី២ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ដែលមានប័ណ្ណសំគាល់ម្ចាស់អចលនវត្ថុលេខ ១៥២២៣ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ ១៩៩៣ ឱ្យទៅអ្នកស្រី ឈឹម វត្តី កាន់កាប់ជាកម្មសិទ្ធិតទៅ ។

៧- ទ្រព្យសម្បត្តិរួម ដែលមានតាមបញ្ជីរាយទ្រព្យសម្បត្តិ រួមចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ ២០០០ លើកលែងតែផ្ទះលេខ១៥០$E_0$ $E_1$ $E_2$ $E_3$ ផ្លូវលេខ១៤៨ សង្កាត់ផ្សារកណ្តាលទី២ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ដែលជាទ្រព្យដើមចេញ ត្រូវបែងចែកជាពីរស្មើគ្នា ចំពោះទ្រព្យណាដែលមានមុនលក្ខន្តិកៈ ក្រុមហ៊ុនLT LUXថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៩៤ ហើយទ្រព្យសម្បត្តិណា ដែលមានក្រោយថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៩៤ ត្រូវទុកឱ្យធ្វើការបែងចែកគ្នា ក្នុងបណ្តឹងបែងចែកភាគហ៊ុន ។

៨- បង្គាប់ឱ្យគូភាគី រួមគ្នាសងបំណុលដែលមានមុនថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៩៤ ហើយបំណុល ដែលមានក្រោយថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៩៤ ត្រូវឱ្យគូភាគីសងតាមការសំរេច ក្នុងរឿងបែងចែកភាគហ៊ុន ។

៩- រឹបអូសប្រាក់ប្រដាប់ក្តី ជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០រៀល ដែលឈ្មោះ ឈឹម វត្តី បានបង់រួចហើយ គឺពន្ធហ្នឹង និង ពន្ធចុះបញ្ជីក្តីចំនួន២៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន៤៥០រៀល ចំណាយលើការប្រគល់ដីកាកោះ ៥.០០០រៀល និង លើអាជ្ញាធរតុលាការ ៥.០០០ រៀល សរុប ១៣.០០០រៀល ។

១០- សាលដីកានេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខចុងចម្លើយ និង មេធាវីការពារចុងចម្លើយ កំបាំងមុខដើមចោទ បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងទាស់លេខ៦៣ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០០១របស់ឈ្មោះថាច់ វ៉ាន់-ឡូន ប្តឹងមិន សុខចិត្តនិងសាលដីកាលេខ១៤៤ "ឈ" ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍លើសេចក្តីសំរេចទាំង មូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ១៩ "ឈ" ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១- ទទួលពាក្យបណ្តឹងទាស់ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០០១ របស់ឈ្មោះ ថាច់ វ៉ាន់ឡូន ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់ និង គតិច្បាប់ ។

២- តំកល់សាលដីកាកំបាំងមុខលេខ១៤៤ "ឈ" ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ទុកជាបានការដដែល ។

៣- សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខគូក្តីបើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ៩៥ ចុះថ្ងៃទី១៣ខែមីនា ឆ្នាំ២០០២របស់ឈ្មោះទូច លុច (មេធាវីរបស់ឈ្មោះថាច់ វ៉ាន់ឡូន) ប្តឹងមិន សុខចិត្តនិងសាលដីកាលេខ១៩ "ឈ" ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍លើសេចក្តីសំរេចទាំង មូល ។

បានឃើញសារណាការពារ ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០០២ របស់ឈ្មោះ ថាច់ វ៉ាន់ឡូន។

បានឃើញសារណាតប ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០២ របស់ឈ្មោះឈឹម វត្តី ។

បានឃើញសារណាបំភ្លឺបន្ថែម ចុះថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០២ របស់ឈ្មោះ ថាច់ វ៉ាន់ឡូន ។

- បានស្តាប់ចៅក្រមរបាយការណ៍អានរបាយការណ៍

- បានស្តាប់តំណាងមហាអយ្យការ បានធ្វើសេចក្តីសន្និដ្ឋាន ថា : សាលដីការដ្ឋប្បវេណីលេខ ១៤៤"ឈ" ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ហើយ ។

អាស្រ័យហេតុនេះសូមក្រុមប្រឹក្សាជំនុំជំរះមេត្តាពិនិត្យ និង សំរេច ។

បានស្តាប់ចម្លើយរបស់ឈ្មោះ ថាច់ វ៉ាន់ឡូន នៅពេលជំនុំជំរះថា : បានជាខ្លួនបានប្តឹងសាទុក្ខ ព្រោះខ្លួនបានមិនសុខចិត្ត និង ការសំរេចសេចក្តីរបស់សាលាឧទ្ធរណ៍ លើបីចំនុច :

១- ការសំរេចសេចក្តីផ្ទុយនឹងច្បាប់ អាពាពិពាហ៍ពិពាហ៍

២- ការយល់ឃើញរបស់សាលាឧទ្ធរណ៍ មានភាពមិនប្រក្រតី

៣- ការសំរេចសេចក្តី លើសសំណូមពរ : ដោយសំរេចយកទ្រព្យសម្បត្តិរួម អោយទៅជាទ្រព្យសម្បត្តិដើមរបស់នាងឈឹម វត្តី ហើយខ្លួន ក៏ដូចជានាង បានសុំបែងចែកពាក់កណ្តាលម្នាក់ ។ ហើយរឿងបំណុល សាលាឧទ្ធរណ៍បានសំរេចអោយខ្លួន និងនាងរួមគ្នាសង ទាំងម្ចាស់បំណុលមិនបានប្តឹងទាមទារផង ។ ហើយចំពោះផ្ទះលេខ១៥០$E_0$ $E_1$ $E_2$ $E_3$ ខ្លួនបានលក់រេស្តូរង់ចតុមុខ យកលុយមកទិញផ្ទះនេះ ហើយដោយនាង វត្តី ជាអ្នក ធ្វើការនៅនាយកដ្ឋាននោះស្រាប់ ទើបនាយកដ្ឋាន ដាក់ឈ្មោះនាង ។ នាងបានឈ្មោះ ជាម្ចាស់ផ្ទះនេះលួចទៅធ្វើប័ណ្ណគ្រួសារ និង ធ្វើប័ណ្ណកម្មសិទ្ធិ ។

ខ្លួន សូមសំណូមពរតុលាការ បែងចែកទ្រព្យសម្បត្តិជាពីរចំនែកស្មើគ្នា ។

បានស្តាប់ចម្លើយរបស់ឈ្មោះ ឈឹម វត្តី នៅពេលជំនុំជំរះថា : នៅពេលដែលខ្លួនមានឯកសារគ្រប់គ្រាន់ ក្នុងការកាន់កាប់ផ្ទះ សំអាងការលុច្បនេះ ដោយមិនបានលួចលាក់ទៅធ្វើលិខិតអ្វីនោះទេ ព្រោះនៅជំនាន់នោះ ជាជំនាន់រដ្ឋកម្ពុជា លោកថានេះពុំត្រឹមត្រូវទេ គឺខ្លួនព្រមទាំងគ្រួសារទេ ដែលផ្តិតមេ ដៃទទួលស្គាល់គាត់មកនៅក្នុងផ្ទះខ្លួន។ នៅឆ្នាំ១៩៨៧ គាត់និយាយថា បើគាត់ជាអ្នកសាងសងផ្ទះនេះ សូមអោយគាត់បង្ហាញលិខិតទាំងនោះមក តាមការពិត គឺគាត់គ្មានលិខិតអ្វីទាំងអស់ ។ ហើយគ្មានលិខិតស្នាមណា ដែលបញ្ជាក់ថាខ្លួន និង លោកថាន់ វ៉ាន់ឡុន ជាប្តីប្រពន្ធ និង គ្នានោះទេ ហើយទ្រព្យសម្បត្តិ ផ្សេងៗដែលសាលាឧទ្ធរណ៍កាត់ក្តី គឺជាទ្រព្យដែលបានកើតចេញពីក្រុមហ៊ុន L T LUX ។

បានស្តាប់ការសន្និដ្ឋានរបស់លោកមេធាវី ទូត លុច នៅពេលជំនុំជំរះថា ខ្លួនសុំលើកពីរឿងពាក់ព័ន្ធនឹងប្តីប្រពន្ធ និង ផ្ទះលេខ១៥០$E_0$ $E_1$ $E_2$ $E_3$ ។ ចំពោះរឿងប្តីប្រពន្ធ ថ្វីត្បិតតែលោក និងអ្នកស្រីមិនបានចុះអេតាស៊ីវិលមែន ប៉ុន្តែនៅជំនាន់នោះមានប្តីប្រពន្ធជាច្រើន ដែលមិនបានចុះអេតាស៊ីវិលដោយអ្នកទាំងនោះរស់នៅជាមួយគ្នាមុនមានច្បាប់ លោកបានរស់នៅឆ្នាំ១៩៨៩ដូច្នេះ គាត់ពុំបាន ចុះអេតាស៊ីវិលទេ ហើយឆ្នាំ២០០២នេះ ច្បាប់បានចេញមកអោយអ្នកដែលគ្មានអេតាស៊ីវិល ទៅចុះអេតាស៊ីវិល ដូច្នេះបានន័យថា ច្បាប់នៅតែទទួលស្គាល់អ្នកដែលគ្មានអេតាស៊ីវិល ។ ចំពោះផ្ទះលេខ១៥០$E_0$ $E_1$ $E_2$ $E_3$ ការផ្តល់អោយដោយនាយកដ្ឋានសិល្បៈនៅលើលិខិតនោះមានការកែ បន្ថែម មានន័យថា នាយកដ្ឋានបានប្រគល់អោយតែមួយចំណែក ។ ឆ្នាំ១៩៩៤ មានការប្រជុំគ្នាមួយទៀត ពេលនោះមានការដោះដូរ គឺខាងលោក និង អ្នកស្រីបានចេញប្រាក់ពីរម៉ឺនដុល្លា ចេញអោយទៅនាយកដ្ឋាន។ ដូច្នេះផ្អែកតាមឯកសាររបស់លោក និង គ្រួសារ បញ្ជាក់ថា ផ្ទះនេះជាទ្រព្យសម្បត្តិរួម ព្រោះអ្នកទាំងពីរជាប្តីប្រពន្ធនឹងគ្នា ។ ចំនុចមួយទៀត សាលាឧទ្ធរណ៍សំរេចលើសពីការស្នើសុំ ដូច្នេះសេចក្តីសំរេចរបស់សាលាឧទ្ធរណ៍មានលក្ខណៈខុសឆ្គង ទាំងទំរង់ និង គតិច្បាប់។ ខ្លួនសុំអោយតុលាការមេត្តាបដិសេធសាលដីកានេះចោលទាំងស្រុង ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកមេធាវី ការ សារុត្ថ នៅពេលជំនុំជំរះថា : ខ្លួនពុំលើកយកអង្គហេតុមកពិចារណាទេ គឺសុំលើកអង្គច្បាប់ ថាតើប្តីប្រពន្ធដែលស្របច្បាប់យ៉ាងណា ព្រោះថាចំណងអាពាហ៍ពិពាហ៍ធ្វើត្រូវស្របច្បាប់ និងតាមក្បួនខ្នាត ។ ហើយតាមច្បាប់អាពាហ៍ពិពាហ៍ បើចំណងអាពាហ៍ពិពាហ៍មុនមិនទាន់រំលាយ មិនទាន់មានសាលក្រមលែងលះ យើងមិនអាចរៀបអាពាហ៍ពិពាហ៍បានទេ គឺផ្ទុយនិងច្បាប់ ហើយចំពោះរដ្ឋធម្មនុញ្ញចែងច្បាស់ថា ប្តីមួយប្រពន្ធមួយ មិនមែនប្តីមួយប្រពន្ធពីរនេះទេ ដូច្នេះអ្នកស្រីនឹងលោកមិនមែនជាប្តីប្រពន្ធស្របច្បាប់នោះទេ ព្រោះលោកថាច់ វ៉ាន់ឡូនគាត់មានប្រពន្ធនៅប្រទេសបារាំង មិនទាន់បានធ្វើការលែងលះដាច់ស្រេចទេ ទើបនៅឆ្នាំ២០០០នេះ បានមានសាលក្រមលែងលះ ។ ហើយចំពោះទ្រព្យសម្បត្តិ អិល.គេ.លុច្ស នេះមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា របស់ ឈឹម វត្តី ចំពោះទ្រព្យសម្បត្តិរួម និងទ្រព្យសម្បត្តិដោយឡែក សូមអោយលោកមេធាវី ហាក់ សៀកលី ជាអ្នកបញ្ជាក់ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកមេធាវី ហាក់ សៀកលី នៅពេលជំនុំជំរះថា : ចំពោះអង្គហេតុខ្លួនបានការពារតាំងពីតុលាការថ្នាក់ក្រោមមក ខ្លួនបានសិក្សាគ្រប់គ្រាន់ពាក់ព័ន្ធ និងការរួមរស់ជាមួយគ្នារបស់អ្នកស្រី វត្តី និង លោក ថាច់ វ៉ាន់ឡូន ។ សាលាឧទ្ធរណ៍បានសំរេចសេចក្តីមកថាភាគីទាំង ពីរបានរស់នៅជាមួយគ្នាតាំងពីឆ្នាំ១៩៩០នោះ គឺជាការយល់ឃើញតាមការអះអាងរបស់ភាគីទេ មិនមែនជាការសំរេច របស់តុលាការទេ ។ តែបើតាមភស្តុតាងគឺនៅឆ្នាំ១៩៩២ ទើបរស់នៅជាមួយគ្នាហើយក្នុងពេលដែលអ្នកទាំងពីរស្រលាញ់គ្នា ទើបអ្នកស្រីប្រគល់សិទ្ធិអោយគាត់ ធ្វើជាមេគ្រួសារមិនមែនបញ្ជាក់ ថា គាត់ជាម្ចាស់ផ្ទះនោះទេ ហើយចំពោះលុយ២០.០០០ដុល្លា គឺជាការទូទាត់បន្ទប់តូចមួយទេមិនមែន ទិញផ្ទះលេខ១៩០$E_0$ $E_1$ និង $E_2$ នោះទេ ។ ហើយចំពោះចំណងអាពាហ៍ពិពាហ៍ គឺដូចលោកមេធាវី ការ សារុត្ថ បានលើកឡើងបញ្ជាក់ជូនរួចហើយ ។ ហើយក្នុងការដែលលោក ថាច់ វ៉ាន់ឡូនទទួលស្គាល់ ថាជាប្តីប្រពន្ធនោះ គឺគាត់ខ្លាចមានទោសព្រហ្មទ័ណ្ឌនោះទេ ដោយគាត់បានក្បត់ទំនុកចិត្តក្នុងរឿងព្រហ្មទ័ណ្ឌលួចស៊ីញ៉េបិទក្រុមហ៊ុន ។ ហើយដែលថាសាលាឧទ្ធរណ៍សំរេចលើសនោះ គឺសាលាឧទ្ធរណ៍ពុំបាន សំរេចលើសទេ គឺគ្រាន់តែសំរេចតំរូវតាមសាលក្រមរបស់តុលាការថ្នាក់ក្រោមដែលមិនបានពិចារ-ណា ព្រោះនៅតុលាការថ្នាក់ក្រោមគ្រាន់តែចប់ការដេញដោលតុលាការប្រកាសភ្លាម មិនបានធ្វើការពិភាក្សាទេ ។ ខ្លួនសុំសំណូមពរតុលាការ សូមអោយបែងចែកទ្រព្យសម្បត្តិតាម អធិការកិច្ច ព្រោះភាគហ៊ុន និង បំណុលផ្សេងៗ អធិការកិច្ចបានធ្វើការបែងចែក នៅក្នុងកំណត់ហេតុនោះស្រាប់ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកមេធាវីទូត លុច នៅពេលជំនុំជំរះថា : តបទៅនឹងលោកមេធាវី ការ សារុត្ថថា អ្នកស្រីគ្មានភស្តុតាងណាបញ្ជាក់ថា ជាប្តីប្រពន្ធនឹងគ្នា ខ្លួនទៅតែសុំបញ្ជាក់ដដែល ថាកាលពីសម័យនោះមិនទាន់មានការចុះអេតាស៊ីវិលទេ គឺរស់នៅជាមួយគ្នាមុនច្បាប់ចេញ ។

ប្រភពពីការធ្វើប័ណ្ណកម្មសិទ្ធិដើម្បី ស្រាវជ្រាវទ្រព្យសម្បត្តិនេះ អ្នកស្រីក៏បានទទួលស្គាល់ថា លុយ ២០.០០០ ដុល្លានេះ ជាលុយរួមដូរនិងបន្ទប់មួយ នេះគឺជាទ្រព្យសម្បត្តិរួមដែរ ហើយចុះលុយថ្លៃជូសជុល ផ្ទះនោះក៏ជាលុយរួមដែរ សូមតុលាការពិចារណាចំពោះរឿងនេះ ។ លោកមេធាវី ហាក់ សៀកលី ថា កូន ក្តីខ្លួនមានរឿងព្រហ្មទ័ណ្ឌនោះ មិនអាចកើតមានឡើងបានទេ ទោះបីជាលោកនៅអសង្ហាសបុគ្គលក៏ ដោយ ។ ដូចនេះខ្លួននៅតែសុំអះអាង ដដែលដែរថា សាលាឧទ្ធរណ៍សំរេចលើសពីការស្នើសុំដដែល ។

បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់លោកមេធាវី ការ សារវុត្ថ នៅពេលជំនុំជំរះថា : ចំពោះ រឿងលុយ២០.០០០ដុល្លា និង លុយថ្លៃជួសជុលគឺតុលាការសំរេចអោយទៅអ្នកស្រី ឈឹម វត្តី ចិញ្ចឹមកូន ព្រោះអ្នកស្រីបានចិញ្ចឹមកូនតែម្នាក់ឯង ។

បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់លោកមេធាវី ហាក់ សៀកលី នៅពេលជំនុំជំរះថា សាលាឧទ្ធរណ៍មិនបានសំរេចលើសទេ ព្រោះនៅក្នុងចំនុចទី៧ សាលាឧទ្ធរណ៍បានសំរេចសារឡើងវិញ ហើយបានអះអាងពីបញ្ហាសងបំណុលក្តី និង បញ្ហាបែងចែកទ្រព្យសម្បត្តិក្តី គឺសាលាឧទ្ធរណ៍សំរេចគ្រប់ - គ្រាន់ហើយមិនលើសទេ ។ សំណូមពរចុងក្រោយសូមអោយតុលាការតំកល់សាលដីកាសាលាឧទ្ធរណ៍ ។

បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់លោកមេធាវី ទូត លុច នៅពេលជំនុំជំរះថា : ទ្រព្យសម្បត្តិនៅឆ្នាំ១៩៩៤ ជាទ្រព្យសម្បត្តិរួម ដូច្នេះត្រូវបែងចែក ៣០% ទៅ៧០%មិនត្រូវបែងចែក ៧០% មក៣០% នោះទេ ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់គូភាគី និង សេចក្តីសន្និដ្ឋានការពារ របស់មេធាវី គូភាគី ។
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៩៥ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០២ របស់លោក ទូត លុច ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃ ច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ការលើករឿងរបស់លោក ថាច់ វ៉ាន់ឡុន ក្នុងសារណាចុះថ្ងៃទី២៤ ខែ កក្កដា ឆ្នាំ២០០២ ថា លោកនិងអ្នកស្រី ឈឹម វត្តី ជាប្តីនិងប្រពន្ធនឹងគ្នា ដោយសំអាងលើសៀវភៅស្នាក់ នៅលេខ ១០៤៩ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ១៩៩៩ ប័ណ្ណគ្រួសារលេខ ២២D ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ

១៩៩៦ និងលេខ២២D ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៩៣ ប័ណ្ណកម្មសិទ្ធិផ្ទះសំអាងការលុច្ស សំបុត្រកំណើតកូនចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ១៩៩៥ ចំលើយរបស់អ្នកស្រី ឈឹម វត្តី ក្នុងកំណត់ហេតុចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០០ និង លិខិតអ្នកស្រី ឈឹម វត្តី ផ្ញើរជូនធនាគារអង្គរ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០០០ នោះគឺជាការភ័ន្តច្រឡំ ពីព្រោះថា :

+ តាមចំលើយលោក ថាច់ វ៉ាន់ឡុន ខ្លួនឯងនាសវនាការនៅតុលាការថ្នាក់ក្រោម ថាខ្លួនពិតជាបាន រួមរស់ជាមួយអ្នកស្រី ឈឹម វត្តី ដោយពុំបានរៀបការ រឺចុះសំបុត្រអាពាហ៍ពិពាហ៍ តាមលក្ខណៈច្បាប់ឡើយ តែលោក និង អ្នកស្រីឈឹម វត្តី ពិតជាមានកូនស្រីម្នាក់ជាមួយគ្នាប្រាកដមែន ។

+ តាមអំណាចសាលក្រម លេខRG ៩៤០៣០៥១ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៩៥ របស់តុលាការទីក្រុង វ៉ាឡង់ប្រទេសបារាំង បញ្ជាក់ឱ្យឃើញថា : តុលាការទើបបានបំបែក លំនៅសង្វាស រវាងខ្លួនលោក ថាច់ វ៉ាន់ឡុន និងប្រពន្ធលោកឈ្មោះ ថាច់ ធីចន្ទា ជាបណ្តោះអាសន្ន ហើយទើបតែមកដល់ឆ្នាំ ២០០០ តុលាការដដែលបានសំរេច រំលាយចំណង អាពាហ៍ពិពាហ៍របស់អ្នកទាំងពីរ ។

+ តាមលិខិតបញ្ជាក់លេខ ១៩៥ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០១ របស់អ្នកស្រី ប៉ែន អ៊ិន ចៅសង្កាត់ផ្សារកណ្តាលII បញ្ជាក់ថា អ្នកស្រី ឈឹម វត្តី និង លោក ថាច់ វ៉ាន់ឡុន ពុំបានរៀបការ និងចុះសំបុត្រអាពាហ៍ពិពាហ៍ជាមួយគ្នា ក្នុងបញ្ជីអត្រានុកូលដ្ឋាននៅសង្កាត់ផ្សារកណ្តាល II នេះទេ ។ បើទោះជាលោក ថាច់ វ៉ាន់ឡុន និង អ្នកស្រីឈឹម វត្តី ជាប្តីប្រពន្ធពេញលេញច្បាប់ក៏ដោយ ក៏ចំណងអាពាហ៍ពិពាហ៍នេះត្រូវមោឃៈភាពដោយមាត្រា៣ , ៦ ,២៤ ,៣៨ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ និងមាត្រា ៤៥ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាដែរ ។

- យល់ឃើញថា ផ្ទះសំអាងការលុច្ស ស្ថិតនៅផ្លូវលេខ៤១ កែងផ្លូវ១៤៨ សង្កាត់ផ្សារកណ្តាល II ខ័ណ្ឌដូនពេញ ដែលលោក ថាច់ វ៉ាន់ឡុន ថាជាសម្បត្តិរួមប្តីប្រពន្ធនោះគឺពុំត្រឹមត្រូវទេពីព្រោះថា :

+ មានភស្តុតាងបញ្ជាក់ថា ផ្ទះលេខ១៥០$E_0$ $E_1$ $E_2$ $E_3$ ពិតជាកម្មសិទ្ធិដើមដោយឡែករបស់អ្នកស្រី ឈឹម វត្តី និង សមាជិកគ្រួសារក្នុងបន្ទុក មុនពេលរួមរស់ជាមួយលោកថាច់ វ៉ាន់ឡុន តាមលិខិតបញ្ជាក់លេខ ១២៨/៩២ លម ចុះថ្ងៃទី២១ ខែ មេសា ឆ្នាំ១៩៩២ របស់ចៅសង្កាត់ផ្សារកណ្តាល II បញ្ជាក់ថា នាងឈឹម វត្តី ជាសិល្បៈការិនី ក្រសួងឃោសនាការវប្បធម៌ ជាម្ចាស់ផ្ទះលេខ ១៥០$E_0$ $E_1$ $E_2$ $E_3$ ដែលមានប័ណ្ណគ្រួសារលេខ ៤៨០ សៀវភៅលេខ២២D រស់នៅក្នុងមូលដ្ឋានសង្កាត់ផ្សារកណ្តាល II ប្រាកដមែន ។

+ តាមវិញ្ញាបនប័ត្រស់គាល់ម្ចាស់ អចលនវត្ថុ(ដើម) ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ ១៩៩២ បញ្ជាក់ថា នាងឈឹម វត្តី ជាមេគ្រួសារ និងជាម្ចាស់ពិតប្រាកដលើអចលនវត្ថុនេះតែម្នាក់ឯង

ដោយមានចុះហត្ថលេខា សមាជិកគណកម្មការ ចំរុះឈ្មោះ ឃី ម៉ាច និង នូវ គឹមសួន ទៀតផង ស្របទៅនិង លិខិតអនុញ្ញាតិ របស់នាយកដ្ឋាន សិល្បៈ និងទស្សនីយភាព របស់ក្រសួងឃោសនាការ និង វប្បធម៌ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ១៩៩១ គឺបានប្រគល់ផ្ទះសំអាងការលុច្ស លេខ១៥០$E_0$ $E_1$ $E_2$ អោយអ្នកស្រី ឈឹម វត្តី ដែលជាអតីតៈសិល្បការនី មុនពេលជួបលោកថាច់ វ៉ាន់ឡុន ផងដែរ ។

- យល់ឃើញថា ការដែលមេធាវីដើមចោទ លើកឡើងថា ប្រាក់២០.០០០ដុល្លា ដែលអ្នកស្រី ឈឹម វត្តី យកទៅទូទាត់ក្នុងការផ្ទេរសំអាងការលុច្ស ពីនាយកដ្ឋានសិល្បៈ និង ទស្សនីយភាពថា ជាប្រាក់ដែលអ្នកស្រី ឈឹម វត្តីបានមកពីការរកស៊ី ក្នុងក្រុមហ៊ុនជាមួយលោក ថាច់ វ៉ាន់ឡុន ដូច្នេះផ្ទះនេះ ជាសម្បត្តិរួមនោះ គឺជាការពុំត្រឹមត្រូវទេ ពីព្រោះក្នុងការប្រកបមុខរបរនេះ អ្នកស្រី ឈឹម វត្តី និងលោក ថាច់ វ៉ាន់ឡុន ស្ថិតក្នុងស្ថានភាពជាសមាជិក ភាគហ៊ុនដូចគ្នា ដែលតាមលក្ខន្តិក នៃក្រុមហ៊ុនគឺ៧០% ៣០% ។

- យល់ឃើញថា ការដែលលោកថាច់ វ៉ាន់ឡុនក្តី មេធាវីរបស់លោកក្តីអះអាងថា ប័ណ្ណសំគាល់សិទ្ធិកាន់កាប់មានបញ្ជាក់ថា ផ្ទះលេខ១៥០ ជាទ្រព្យរួមប្តីប្រពន្ធនោះ គឺជាការពុំត្រឹមត្រូវទេ ពីព្រោះថា ប័ណ្ណកម្មសិទ្ធិនេះធ្វើឡើង នៅលើមូលដ្ឋាន នៃប្រកាសរបស់សាម៉ីខ្លួនដែលមិនត្រឹមត្រូវតាមច្បាប់ ។

- យល់ឃើញថា ការដែលលោក ថាច់ វ៉ាន់ឡុនក្តី មេធាវីរបស់លោកក្តីអះអាងថា ផ្ទះលេខ១៥០$E_0$ $E_1$ $E_2$ $E_3$ នេះ លោកទិញពីនាយកដ្ឋានសិល្បៈ និង ទស្សនិយភាពនោះ ពុំមានភស្តុតាងណាមួយបញ្ជាក់អំពីការអះអាងនេះទេ ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចត្រង់ចំណុចទី៧ នៃសាលដីកាកំបាំងមុខ លេខ ១៤៤ "ឈ" ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ ២០០១ ដែលត្រូវបានសាលាឧទ្ធរណ៍តម្កល់ទុកជាបានការ តាមសាលដីកាចំពោះមុខ លេខ ១៩ "ឈ" ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០០២ គឺជាការភ័ន្តច្រឡំពីព្រោះ តាមពាក្យបណ្តឹងចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០០ អ្នកស្រី ឈឹម វត្តីបានប្តឹងឃាត់សកម្មភាព របស់ក្រុម-ហ៊ុន អិលអេសអេស សង់តាណា ជា បណ្តោះអាសន្ន រង់ចាំការសំរេចដល់អង្គសេចក្តីដែលគប្បី សាលា-ឧទ្ធរណ៍ពិចារណាឡើងវិញ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ១៩ "ឈ" ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែអំពីគតិច្បាប់ខុសខ្លះត្រូវខ្លះ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តីចំពោះមុខ គូក្តី**

១- ទទួលបណ្តឹងសាទុក្ខលេខ ៩៥ ចុះថ្ងៃទី១៣ ខែ០៣ ឆ្នាំ២០០២ របស់លោកមេធាវី

ទូត លុច ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែអំពីគតិច្បាប់ខុសខ្លះត្រូវខ្លះ ។

២- តម្កល់សាលដីការដ្ឋប្បវេណីលេខ ១៩"ឈ"ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ទុកជាបានការលើកលែងចំណុចទី៧ នៃសាលដីកាកំបាំងមុខ លេខ១៤៤"ឈ" ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០១ ដែលត្រូវទុកជាមោឃៈ ។

៣- បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ១៨៦ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០២ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះ ត្រង់ចំណុចទី៧ នៃសាលដីកាកំបាំងមុខលេខ ១៤៤"ឈ" ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ជាថ្មីឡើងវិញ ។

៤- រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ១៩.០០០រៀល ដែលអ្នកស្រី ឈឹម វត្តី បានបង់គឺ :

- ពន្ធចុះបញ្ជីក្តី និង ពន្ធហ្គីងចំនួន ៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ។

- ចំណាយលើការប្រគល់ដីកាកោះចំនួន ១៥.០០០រៀល សរុប១៩.០០០រៀល ហើយតំរូវឱ្យលោក ថាច់ វ៉ាន់ឡូន សងប្រាក់ចំនួន ៩.៥០០រៀលទៅឱ្យអ្នកស្រី ឈឹម វត្តីវិញ ។

៥- សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០២ ។